## រកទីកន្លែងបោះឆ្នោតរបស់អ្នក

ទីកន្លែងបោះឆ្នោតរបស់អ្នក អាចនឹងផ្លាស់ប្តូរក្នុងចន្លោះពេលការបោះឆ្នោត។ ផែកមើលខាងខ្នងនៃព័ត៌មានណែនាំអ្នកបោះឆ្នោត ខោនធីរបស់អ្នក សំរាប់ទីកន្លែងនៃកន្លែងបោះឆ្នោតរបស់អ្នក។ អ្នកក៏អាចរកកន្លែងបោះឆ្នោតរបស់អ្នក ដោយទូរស័ព្ទទៅការិយាល័យបោះឆ្នោត ខោនធីរបស់អ្នក ឬលេខពិសេស អ្នកបោះឆ្នោត របស់រដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬមើល https://voterstatus.sos.ca.gov ឬវាយពាក្យ ‘Vote’ (បោះឆ្នោត) ទៅលេខ ‘govote’។

## លទ្ធផលការបោះឆ្នោត

តើចង់ឃើញលទ្ធផលការបោះឆ្នោត នៅពេលវាចូលមកឬទេ? ទទួលព័ត៌មានការរាប់ឆ្នោតរាល់នាទីក្នុងពេលការបោះឆ្នោត ទូទាំងរដ្ឋ នៅ vote.sos.ca.gov ឬតាម Twitter ដោយតាម @CASOSvote។ ចុះឈ្មោះ សំរាប់សភាពការណ៍ជាអេឡិកត្រូនិក តាមបណ្តាញនៅ https://goo.gl/BB7zb4

## ព័ត៌មានសំរាប់អ្នកបោះឆ្នោត មាន 10 ភាសា

មើល www.sos.ca.gov/elections/voting-california ឬទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោត ឥតចេញថ្លៃណាមួយនៅខាងក្រោម។

### លេខពិសេសអ្នកបោះឆ្នោត

| | |
|---|---|
| English | (800) 345-VOTE (8683) |
| Español / Spanish | (800) 232-VOTA (8682) |
| 中文 / Chinese | (800) 339-2857 |
| हिंदी / Hindi | (888) 345-2692 |
| 日本語 / Japanese | (800) 339-2865 |
| ខ្មែរ / Khmer | (888) 345-4917 |
| 한국어/Korean | (866) 575-1558 |
| Tagalog | (800) 339-2957 |
| ไทย / Thai | (855) 345-3933 |
| Việt ngữ / Vietnamese | (800) 339-8163 |
| TTY / TDD | (800) 833-8683 |

californiasos

casosvote

californiasos_

californiasos




**ថ្ងៃ 5 ខែមិថុនា**
ការបោះឆ្នោតជាបឋម
ផ្ទាល់ទូទាំងរដ្ឋ
**ថ្ងៃ 6 ខែវិច្ឆិកា**
ការបោះឆ្នោតទូទៅ

កន្លែងបោះឆ្នោតបើក
ម៉ោង **7:00 ព្រឹក** ដល់
**8:00 យប់** នៅថ្ងៃបោះឆ្នោត

បោះឆ្នោត រដ្ឋកាលីហ្វ័រនីញ៉ា
www.sos.ca.gov

**California Secretary of State Alex Padilla**
(888) 345-4917

# ចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រនីញ៉ាអ្នកត្រូវតែជា ៖

**ពលរដ្ឋអាមេរិក និងអ្នកមូលដ្ឋាននៃរដ្ឋកាលីហ្វ័រនីញ៉ា;**

**មានអាយុ 18 ឆ្នាំ ឬចាស់ជាង នៅថ្ងៃបោះឆ្នោត;**

**នៅពេលបច្ចុប្បន្ននេះ មិនជាប់ពន្ធនាគារ រដ្ឋ ឬសហព័ន្ធ ឬឋិតក្នុងលក្ខខ័ណ្ឌការដោះលែងសំរាប់ការជាប់ទោសបទឧក្រិដ្ឋ; និង**

**នៅពេលបច្ចុប្បន្ននេះ មិនបានរកឃើញដោយតុលាការ ថាអសមត្ថភាពខាងផ្លូវចិត្ត ដើម្បីបោះឆ្នោតឡើយ។**

អ្នកអាចដាក់ពាក្យសុំតាម អ៊ិនទ័រណិតនៅ www.RegisterToVote.ca.gov ឬរកក្រដាសដាក់ពាក្យសុំ នៅការិយាល័យប្រៃសណីយ៍ បណ្ណាល័យ និងការិយាល័យរដ្ឋាភិបាល មួយចំនួន។ នៅក្នុងករណីភាគច្រើន អ្នកត្រូវតែចុះឈ្មោះយ៉ាងតិចបំផុត ចំនួន 15 ថ្ងៃ មុនថ្ងៃបោះឆ្នោត ទើបអាចបោះឆ្នោតក្នុងការបោះឆ្នោតនោះបាន។

បើសិនអ្នកបានខានចុះឈ្មោះឲ្យទាន់កាលកំណត់ អ្នកអាចចុះឈ្មោះ និងបោះឆ្នោតមានលក្ខខ័ណ្ឌបាន។ ទាក់ទងមន្ត្រីបោះឆ្នោត ខោនធីរបស់អ្នក សំរាប់ព័ត៏មានបន្ថែម។ អ្នកត្រូវតែចុះឈ្មោះសាថ្មី ដើម្បីបោះឆ្នោត បើសិនអ្នកផ្លាស់លំនៅ ឬដូរឈ្មោះ ឬការប្រកាន់គណបក្សនយោបាយរបស់អ្នក។

# ចុះឈ្មោះជាមុន

ដើម្បីចុះឈ្មោះបោះឆ្នោតជាមុន ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា អ្នកត្រូវតែ៖

- មានអាយុ 16 ឬ 17 ឆ្នាំ, និង
- ស្របតាមការតម្រូវផ្សេងៗទៀតទាំងអស់ នៃសិទ្ធិបោះឆ្នោត។

អ្នកនឹងបានចុះឈ្មោះបោះឆ្នោតជាស្វ័យប្រវត្តិ នៅខួបកំណើតទី 18 របស់អ្នក។

# បោះឆ្នោតតាមសំបុត្រ

អ្នកបោះឆ្នោតណាម្នាក់ដែលបានចុះឈ្មោះ អាចបោះឆ្នោតតាមសំបុត្រក្នុងរដ្ឋកាលីហ្វ័រនីញ៉ាបាន។ បំពេញពាក្យសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ នៅក្នុងព័ត៏មានណែនាំអ្នកបោះឆ្នោត របស់អ្នក ឬរកបានមួយនៅ www.sos.ca.gov ឬក៏ទាក់ទងការិយាល័យបោះឆ្នោត ខោនធីរបស់អ្នក។ ក្រដាសដាក់ពាក្យសុំរបស់អ្នកដែលបានបំពេញចប់ ត្រូវតែមកដល់ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក យ៉ាងតិចបំផុតប្រាំពីរថ្ងៃ មុនថ្ងៃបោះឆ្នោត។

ដើម្បីឲ្យប្រាកដថាសន្លឹកឆ្នោតដែលអ្នកបានបោះ បានមកដល់ទាន់កាលកំណត់ សន្លឹកឆ្នោតដែលអ្នកបានបោះ ត្រូវតែបានបោះតាប្រៃសណីយ៍ នៅចំថ្ងៃ ឬនៅមុនថ្ងៃបោះឆ្នោត និងបានទទួល ដោយការិយាល័យបោះ ឆ្នោតខោនធីរបស់អ្នក មិនយឺតជាងបីថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតឡើយ។

អ្នកបោះឆ្នោតទាំងអស់ ដែលបានចុះឈ្មោះក្នុងខោនធី Madera, Napa, Nevada, Sacramento, និង San Mateo នឹងទទួលសន្លឹកឆ្នោតដែលបានផ្ញើ ចំនួន 28 ថ្ងៃ មុនពេលបោះឆ្នោត។ អ្នកបោះឆ្នោតនៅក្នុងខោនធីទាំងប្រាំនេះ ឥឡូវនេះអាចសំរេចចិត្ត បើសិនគេចង់បោះសន្លឹកឆ្នោតរបស់គេ នៅឯមជ្ឈមណ្ឌលបោះឆ្នោតណាមួយ ក្នុងខោនធីរបស់គេ ដល់ទៅ 10 ថ្ងៃ មុនថ្ងៃបោះឆ្នោត តាមរយះប្រៃណីយ៍ ឬនៅឯកន្លែងទំលាក់សន្លឹកឆ្នោត ដែលបិតថេរ។ សំរាប់ព័ត៏មានបន្ថែម សូមទាក់ទងការិយាល័យបោះឆ្នោត ខោនធីរបស់អ្នក ឬទៅមើលតាមបណ្តាញ www.sos.ca.gov/elections/voters-choice-act។

# ការបោះឆ្នោតជាបណ្តោះអាសន្ន

ទោះបើឈ្មោះរបស់អ្នក ឥតមាននៅក្នុងបញ្ជីអ្នកបោះឆ្នោត នៅទីកន្លែងបោះឆ្នោត ក៏អ្នកមានសិទ្ធិបោះឆ្នោតបាន ជាមួយនឹងសន្លឹកឆ្នោតបណ្តោះអាសន្ន នៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ សន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នក នឹងបានរាប់តែបន្ទាប់ពីមន្ត្រីបោះឆ្នោត បានបញ្ជាក់ថាអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ ហើយអ្នកមិនបានបោះឆ្នោតរួចហើយ ក្នុងពេលបោះឆ្នោតនោះទេ។ បុគ្គលិកនៅកន្លែងបោះឆ្នោត អាចផ្តល់ព័ត៏មានឲ្យអ្នក អំពីរបៀបឆែកមើល បើសិនសន្លឹកឆ្នោតបណ្តោះ អាសន្នរបស់អ្នក ត្រូវបានរាប់ និងបើវាមិនបានរាប់ ហើយនិងមូលហេតុអ្វី។ សំរាប់ព័ត៏មានបន្ថែម ស្តីពីស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក មើល https://voterstatus.sos.ca.gov

# ព័ត៏មានសន្លឹកឆ្នោត

អ្នកបោះឆ្នោតដែលបានចុះឈ្មោះ ទទួលព័ត៏មានណែនាំអ្នកបោះឆ្នោត របស់រដ្ឋលេខាធិការ ក្នុងប្រអប់សំបុត្រនៅមួយឬពីរអាទិត្យមុនថ្ងៃបោះ ឆ្នោត។ ការិយាល័យបោះឆ្នោតខោនធី ផ្ញើព័ត៏មានណែនាំអ្នកបោះឆ្នោតខោនធី ទៅឲ្យអ្នកបោះឆ្នោត។ ព័ត៏មានណែនាំអ្នកឥតនិទ្ទាការទាំងនេះ រួមមាន អំពីវិធីសន្លឹកឆ្នោត បេក្ខជន សិទ្ធិការបោះឆ្នោត និងមានច្រើនទៀត។

**ថ្ងៃ 5 ខែមិថុនា | ការបោះឆ្នោតជាបឋមផ្ទាល់ទូទាំងរដ្ឋ**

| | |
|---|---|
| ចុះឈ្មោះបោះឆ្នោត ឲ្យទាន់ | **ថ្ងៃ 21 ខែឧសភា** |
| ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខ័ណ | **ថ្ងៃ 22 ខែឧសភា - ថ្ងៃ 5 ខែមិថុនា** |
| ស្នើសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រឲ្យទាន់ | **ថ្ងៃ 29 ខែឧសភា** |
| ផ្ញើសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ទៅវិញ (ត្រូវតែបានបោះត្រាប្រៃសណីយ៍ ឲ្យទាន់) | **ថ្ងៃ 5 ខែមិថុនា** |

**ថ្ងៃ 6 ខែវិច្ឆិកា | ការបោះឆ្នោតទូទៅ**

| | |
|---|---|
| ចុះឈ្មោះបោះឆ្នោត ឲ្យទាន់ | **ថ្ងៃ 22 ខែតុលា** |
| ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខ័ណ | **ថ្ងៃ 23 ខែតុលា - ថ្ងៃ 6 ខែវិច្ឆិកា** |
| ស្នើសុំសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រឲ្យទាន់ | **ថ្ងៃ 30 ខែតុលា** |
| ផ្ញើសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ ទៅវិញ (ត្រូវតែបានបោះត្រាប្រៃសណីយ៍ ឲ្យទាន់) | **ថ្ងៃ 6 ខែវិច្ឆិកា** |




**RegisterToVote.ca.gov**